អេស៊ីលីដា
ACLEDA BANK

# របាយការណ៍
# ប្រចាំត្រីមាសទី២

គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣

## ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ (គិតជាលានរៀល) | ត្រីមាសទី២ ឆ្នាំ២០២៣ | ឆ្នាំ២០២២ | ឆ្នាំ២០២១ |
|---|---|---|---|
| ទ្រព្យសកម្មសរុប | ៣៩.០៣៣.៨០៤ | ៣៧.១៨១.២៩៩ | ៣២.០០២.២៩៨ |
| បំណុលសរុប | ៣៣.៦២៥.៩១១ | ៣១.៧៦០.៦៦០ | ២៧.០៩២.៩៨៥ |
| មូលធនសរុប | ៥.៤០៧.៨៩៣ | ៥.៤២០.៦៣៩ | ៤.៩០៩.៣១៣ |
| **លទ្ធផលហិរញ្ញវត្ថុ (គិតជាលានរៀល)** | **ត្រីមាសទី២ ឆ្នាំ២០២៣** | **ត្រីមាសទី២ ឆ្នាំ២០២២** | **ត្រីមាសទី២ ឆ្នាំ២០២១** |
| ចំណូលសរុប | ៨៤៤.២២៨ | ៧៥២.០៦៧ | ៦២៥.៥១៧ |
| ចំណេញ/(ខាត) មុនបង់ពន្ធ | ១៧៣.៥០៦ | ២៤៩.៥១៦ | ១៨៧.៥៨៧ |
| ចំណេញ/(ខាត) សុទ្ធក្នុងការិយបរិច្ឆេទ | ១៣៥.៥៧៤ | ១៩៥.៨៦៥ | ១៥០.៧៩៦ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ | ២១៧.២៨២ | ១៥៤.៦៩១ | ១៧៤.១៥៤ |
| **អនុបាតហិរញ្ញវត្ថុ (%)** | **ត្រីមាសទី២ ឆ្នាំ២០២៣** | **ឆ្នាំ២០២២** | **ឆ្នាំ២០២១** |
| អនុបាតសាធនភាព | ១៨,៥៨% | ១៩,២៥% | ២២,៣៦% |
| អនុបាតបំណុលធៀបនឹងមូលធន | ៦២១,៧៩% | ៥៨៥,៩២% | ៥៥១,៨៧% |
| អនុបាតក្របខ័ណ្ឌសន្ទនីយភាព | ១៧០,២៩% | ១៥៤,៩៦% | ១៥៥,៦៥% |
| អនុបាតឥណទានមិនដំណើរការ (*) | ៤,៦៣% | ២,៩០% | ២,៣៣% |
| អនុបាតឥណទានធៀបនឹងប្រាក់បញ្ញើ | ៩៤,៩៣% | ១០០,៥១% | ៩៤,៩៧% |
| តម្លៃចុះបញ្ជីក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល) | ១២.៤២៧ | ១២.៤៥៦ | ១១.២៧៧ |
| | **ត្រីមាសទី២ ឆ្នាំ២០២៣** | **ត្រីមាសទី២ ឆ្នាំ២០២២** | **ត្រីមាសទី២ ឆ្នាំ២០២១** |
| អនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យម (ROAA)(**) | ០,៣៥% | ០,៥៨% | ០,៥២% |
| អនុបាតចំណេញធៀបនឹងមូលធនមធ្យម (ROAE)(**) | ២,៥០% | ៣,៩៤% | ៣,២៣% |
| អនុបាតលទ្ធភាពបង់ការប្រាក់ (ដង) | ១,៥១ | ២,២១ | ២,០៩ |
| ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល) | ៣១៣,២៥ | ៤៥១,៤៨ | ៣៤៨,៨២ |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | គ្មាន | គ្មាន | គ្មាន |
| អនុបាតហិរញ្ញវត្ថុសំខាន់ៗផ្សេងទៀត | គ្មាន | គ្មាន | គ្មាន |

(*) ឥណទានមិនដំណើរការ = ឥណទាននៅដំណាក់កាលទី៣

(**) . អនុបាតទាំងនេះមិនមែនជាអនុបាតប្រចាំឆ្នាំនោះទេ ហើយត្រូវបានគណនាដោយប្រើតួលេខប្រាក់ចំណេញដែលផ្តល់ជូនដល់ភាគហ៊ុនិករបស់ធនាគាររយៈពេល ៣ខែ ចាប់ពីថ្ងៃទី០១ ខែមេសា ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣។

. អនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យម = ប្រាក់ចំណេញក្នុងការិយបរិច្ឆេទដែលផ្តល់ជូនដល់ភាគហ៊ុនិករបស់ធនាគារ / ទ្រព្យសកម្មសរុបមធ្យម

. អនុបាតចំណេញធៀបនឹងមូលធនមធ្យម = ប្រាក់ចំណេញក្នុងការិយបរិច្ឆេទដែលផ្តល់ជូនដល់ភាគហ៊ុនិករបស់ធនាគារ / មូលធនសរុបមធ្យមរបស់ភាគហ៊ុនិករបស់ធនាគារ

# ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប







អនុបាតហិរញ្ញវត្ថុ (%)
១៨,៥៨%
១៩,២៥%
២២,៣៦%
៦២១,៧៩%
៥៨៥,៩២%
៥៥១,៨៧%
១៧០,២៩%
១៥៤,៩៦%
១៥៥,៦៥%
៤,៦៣%
២,៩០%
២,៣៣%
៩៤,៩៣%
១០០,៥១%
៩៤,៩៧%
អនុបាតសាធនភាព
អនុបាតបំណុលធៀប នឹងមូលធន
អនុបាតក្របខ័ណ្ឌ សន្ទនីយភាព
អនុបាតឥណទាន មិនដំណើរការ
អនុបាតឥណទានធៀប នឹងប្រាក់បញ្ញើ
ត្រីមាសទី២ ឆ្នាំ២០២៣
ឆ្នាំ២០២២
ឆ្នាំ២០២១


០,៣៩%
០,៥៨%
០,៥២%
២,៥០%
៣,៩៤%
៣,២៣%
អនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យម (ROAA)
អនុបាតចំណេញធៀបនឹងមូលធនមធ្យម (ROAE)
ត្រីមាសទី២ ឆ្នាំ២០២៣
ត្រីមាសទី២ ឆ្នាំ២០២២
ត្រីមាសទី២ ឆ្នាំ២០២១


ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល)
៣៤៨,៨២
៤៥១,៤៨
៣១៣,២៥
ត្រីមាសទី២ ឆ្នាំ២០២១
ត្រីមាសទី២ ឆ្នាំ២០២២
ត្រីមាសទី២ ឆ្នាំ២០២៣
ត្រីមាសទី២ ឆ្នាំ២០២១ ត្រីមាសទី២ ឆ្នាំ២០២២ ត្រីមាសទី២ ឆ្នាំ២០២៣


តម្លៃចុះបញ្ជីក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល)
១១.២៧៧
១២.៤៥៦
១២.៤២៧
ឆ្នាំ២០២១
ឆ្នាំ២០២២
ត្រីមាសទី២ ឆ្នាំ២០២៣
ឆ្នាំ២០២១ ឆ្នាំ២០២២ ត្រីមាសទី២ ឆ្នាំ២០២៣

# សមាសភាពក្រុមប្រឹក្សាភិបាល



**លោក ឆាយ សឿន**

*ប្រធានក្រុមប្រឹក្សាភិបាល*



**បណ្ឌិត អ៊ិន ចាន់នី**

*អភិបាលប្រតិបត្តិ*



**លោក Stéphane Mangiavacca**

*អភិបាលមិនប្រតិបត្តិ*



**លោក Kyosuke Hattori**

*អភិបាលមិនប្រតិបត្តិ*



**បណ្ឌិត Albertus Bruggink**

*អភិបាលមិនប្រតិបត្តិ*



**លោក កាយ ឡូត**

*អភិបាលមិនប្រតិបត្តិ*



**លោក Pieter Kooi**

*អភិបាលឯករាជ្យ*



**លោក វ៉ាន់ ស៊ូអៀង**

*អភិបាលឯករាជ្យ*



**លោកស្រី ភួរិ រតនា**

*អភិបាលឯករាជ្យ*

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

តាងនាមឱ្យធនាគារ អេស៊ីលីដា ភីអិលស៊ី (“ធនាគារ”) និងក្រុមប្រឹក្សាភិបាល ខ្ញុំបាទមានកិត្តិយស និងសេចក្តីសោមនស្សរីករាយ សូមផ្តល់ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាសទី២ ឆ្នាំ២០២៣ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ធនាគារ (“សម្ព័ន្ធធនាគារ”) គិតចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ ដល់ភាគីពាក់ព័ន្ធទាំងអស់។

នៅក្នុងឆមាសទី១នៃឆ្នាំ២០២៣ សេដ្ឋកិច្ចពិភពលោកបានបង្ហាញពីការធ្វើបច្ចុប្បន្នភាព ជាមួយនឹងកំណើនកម្រិតមធ្យមនៅក្នុងសហរដ្ឋអាមេរិក និងប្រទេសចិន ដែលជាការរំពឹងទុកនៃសញ្ញាណវិជ្ជមាននៃសេដ្ឋកិច្ច បើទោះបីជាមានភាពតានតឹងពីសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន ដែលកំពុងបន្តការកើនឡើងអតិផរណា និងការដំឡើងអត្រាការប្រាក់គោលរបស់ធនាគារកណ្តាលអាមេរិក ដែលជាបញ្ហាប្រឈមក៏ដោយ។ ទន្ទឹមនឹងនេះ សេដ្ឋកិច្ចអាស៊ានក្នុងត្រីមាសទី២ ស្ថិតក្នុងស្ថានភាពល្អប្រសើរជាងត្រីមាសទី១ ឆ្នាំ២០២៣ នេះបណ្តាលមកពីកត្តាមួយចំនួនដូចជាការនាំចេញក្នុងតំបន់បន្តកើនឡើង ការស្ទុះងើបឡើងវិញនៃទេសចរណ៍ និងលំហូរវិនិយោគផ្ទាល់ពីបរទេស (FDI) នៅតែរឹងមាំ។ ស្របពេលជាមួយគ្នានេះដែរ សេដ្ឋកិច្ចកម្ពុជាក៏បានបន្តកើនឡើងក្នុងត្រីមាសទី២ ឆ្នាំ២០២៣ បើទោះបីជាមាន កំណើនយឺតជាងត្រីមាសទី១ ក៏ដោយ។ ការថមថយកំណើននេះគឺដោយសារតែកត្តាមួយចំនួនរួមទាំងសង្គ្រាមរុស្ស៊ី-អ៊ុយក្រែនដែលកំពុងបន្ត ដែលបានជះឥទ្ធិពលដល់ខ្សែច្រវាក់ផ្គត់ផ្គង់ពិភពលោក និងនាំឱ្យតម្លៃថាមពលកើនឡើងខ្ពស់។ ទោះបីជាយ៉ាងនេះក្តី ក៏សេដ្ឋកិច្ចកម្ពុជានៅតែរក្សាកំណើនប្រមាណ ៥,៥% នៅឆ្នាំ២០២៣។ កំណើននេះត្រូវបានជំរុញដោយកត្តាមួយចំនួន រួមមាន ការងើបឡើងវិញនៃវិស័យទេសចរណ៍ ភាពរឹងមាំនៃផលិតកម្មកសិកម្ម និងការបន្តការវិនិយោគលើវិស័យកាត់ដេរ។

នៅកំលុងត្រីមាសទី២ ឆ្នាំ២០២៣នេះ ធនាគារ អេស៊ីលីដា បានទទួលការអនុញ្ញាតពី ធនាគារជាតិ នៃ កម្ពុជា ជាធនាគារទូទាត់នៅក្នុងប្រព័ន្ធប្រតិបត្តិការទូទាត់ឆ្លងដែនតាមរយៈឃ្យូអរ រវាងប្រទេសកម្ពុជា និងថៃ ក៏ដូចជាប្រទេសវៀតណាម ព្រមទាំងកំពុងដំណើរការរៀបចំជាជំហានបន្ទាប់ទៅប្រទេសជាសមាជិកអាស៊ាន។

ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធនេះ គឺក្នុងគោលបំណងដើម្បីរួមចំណែកលើកកម្ពស់ការទូទាត់រូបិយវត្ថុជាតិ ព្រមទាំងរួមចំណែកយ៉ាងសំខាន់ក្នុងការជំរុញបរិយាបន្នហិរញ្ញវត្ថុ សម្រួលការធ្វើពាណិជ្ជកម្មឆ្លងដែន និងកំណើនភ្ញៀវទេសចរ ផងដែរ។ ដូចនេះ អ្នកប្រើប្រាស់ **អេស៊ីលីដាម៉ូបាល** អាចស្កេនឃ្យូអរទូទាត់ថ្លៃទិញទំនិញ និងសេវាកម្មផ្សេងៗ ជាប្រាក់រៀល ក្នុងប្រទេសថៃ និងវៀតណាម ដោយឥតគិតថ្លៃ។ បន្ថែមលើនេះ ធនាគារ អេស៊ីលីដា បានសហការជាមួយនឹងស្ថាប័ន Global Loyalty Network "GLN International Inc." ដើម្បីដាក់ឱ្យប្រើប្រាស់នូវសេវាទូទាត់ឆ្លងដែន តាមឃ្យូអរកូដ GLN CPM QR សម្រាប់ស្កេនជាមួយម៉ាស៊ីន POS នៅប្រទេសកម្ពុជា។ ធនាគារបានបន្តធ្វើឱ្យប្រសើរឡើងនូវមុខងារស្វ័យប្រតិបត្តិការជាច្រើនលើ**អេស៊ីលីដាម៉ូបាល** ឃ្យូអរកូដ ម៉ាស៊ីនអេធីអឹម និងម៉ាស៊ីនឆូតកាត ស្របតាមតម្រូវការរបស់អតិថិជន និងវិវឌ្ឍនាការបច្ចេកវិទ្យាឌីជីថល។ ទន្ទឹមនឹងនេះ ធនាគារបានពង្រីកសេវាកម្មធនាគារស្វ័យប្រវត្តិចំនួន**១៤៨**ទីតាំង (រាជធានីភ្នំពេញចំនួន**៥៨**ទីតាំង និងបណ្តាខេត្តសរុបចំនួន**៩០**ទីតាំង) បន្ថែមលើសាខាធនាគារទាំង**២៦៤**សាខា។ ធនាគារបានបំពាក់ម៉ាស៊ីនអេធីអឹមចំនួន **១.២៤៦**គ្រឿង ម៉ាស៊ីនឆូតកាតចំនួន**៤.២១០**គ្រឿង និងឃ្យូអរកូដតាមសំណើសុំរបស់អតិថិជនសម្រាប់ប្រតិបត្តិការនៃការផ្ទេរ និងការទូទាត់នៅតាមបណ្តាផ្សារ ហាងទំនិញ សណ្ឋាគារ ភោជនីយដ្ឋាន គ្រឹះស្ថានសិក្សា មន្ទីរពេទ្យ ទីភ្នាក់ងារទេសចរណ៍ ស្ថានីយ៍ប្រេងឥន្ធនៈ និងអាជីវកម្មនានា នៅទូទាំងប្រទេស។ គិតត្រឹមដំណាច់ត្រីមាសទី២ ឆ្នាំ២០២៣នេះ ធនាគារមានដៃគូអាជីវកម្មសរុបជាង**០,២៧លាន** និងមានអ្នកប្រើប្រាស់**អេស៊ីលីដាម៉ូបាល** សរុបចំនួន**២,៩៦លាន**នាក់។

គិតត្រឹមដំណាច់ត្រីមាសទី២ ឆ្នាំ២០២៣នេះ ទ្រព្យសកម្មសរុបរបស់សម្ព័ន្ធធនាគារ បានកើនឡើងចំនួន៤២០,១២លានដុល្លារអាមេរិក ឬ៤,៦៥% និងទ្រព្យសកម្មឥណទានសរុបបានកើនឡើងចំនួន១២៥,៩៨លានដុល្លារអាមេរិក ឬ១,៩៦% ធៀបនឹងដំណាច់ឆ្នាំ២០២២។

សម្ព័ន្ធធនាគារទទួលបានប្រាក់ចំណេញដែលផ្តល់ជូនភាគហ៊ុនិករបស់ធនាគារ (សម្រាប់ខែមេសា ឧសភា និងមិថុនា ឆ្នាំ២០២៣) សរុបចំនួន៣៣,០៧លានដុល្លារអាមេរិក ខណៈដែលអនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យមមានចំនួន០,៣៥% និងអនុបាតចំណេញធៀបនឹងមូលធនមធ្យមមានចំនួន២,៥០%។

ជាទីបញ្ចប់ ខ្ញុំបាទសូមថ្លែងអំណរគុណ និងសំដែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅ ចំពោះភាគីពាក់ព័ន្ធទាំងអស់ដែលបានបន្តផ្តល់ការជ្រោមជ្រែង និងការគាំទ្រដល់ធនាគារ។

ថ្ងៃព្រហស្បតិ៍ ៩រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៣
ហត្ថលេខា និងត្រា

ធនាគារ អេស៊ីលីដា ភីអិលស៊ី
ACLEDA BANK PLC.

**ឆាយ សឿន**

# មាតិកា

ព័ត៌មានហិរញ្ញវត្ថុសង្ខេប ........ i

ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប ........ ii

សមាសភាពក្រុមប្រឹក្សាភិបាល ........ v

សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល ........ vi

ផ្នែកទី១- ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ ........ ១

ក- អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ ........ ១

ខ- លក្ខណៈនៃធុរកិច្ច ........ ១

គ- ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ........ ១

ផ្នែកទី២- ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ........ ៣

ក- លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក ........ ៣

ខ- រចនាសម្ព័ន្ធចំណូល ........ ៦

ផ្នែកទី៣- របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មដោយសវនករឯករាជ្យ ........ ៦

ផ្នែកទី៤- ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង ........ ៧

ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ........ ៧

ខ- កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ ........ ១០

គ- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល ........ ១១

ឃ- ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ ........ ១២

ង- ផលប៉ះពាល់នៃអតិផរណា ........ ១២

ច- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល ........ ១២

ហត្ថលេខាអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ........ ១៥

# ផ្នែកទី១- ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ

## ក- អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ | **ធនាគារ អេស៊ីលីដា ភីអិលស៊ី** |
| ជាអក្សរឡាតាំង | **ACLEDA Bank Plc.** |
| លេខកូដស្តង់ដារ | KH១០០០១០០០០៣ |
| ទីស្នាក់ការ | អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| លេខទូរស័ព្ទ | +៨៥៥ (០)២៣ ៩៩៨ ៧៧៧ / ៤៣០ ៩៩៩ |
| លេខទូរសារ | +៨៥៥ (០)២៣ ៤៣០ ៥៥៥ |
| គេហទំព័រ | www.acledabank.com.kh |
| អ៊ីម៉ែល | acledabank@acledabank.com.kh |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០០៣០៧៧ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០០ ចេញដោយក្រសួងពាណិជ្ជកម្ម |
| លេខអាជ្ញាបណ្ណអាជីវកម្ម | ០៦ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៦ ចេញដោយ ធនាគារជាតិ នៃ កម្ពុជា |
| សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន | លេខ០៥៣/២០គ.ម.ក./ស.ស.រ. ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ ចេញដោយនិយ័តករមូលបត្រកម្ពុជា “ន.ម.ក.” (ពីមុនជា គណៈកម្មការមូលបត្រកម្ពុជា “គ.ម.ក.”) |
| ឈ្មោះបុគ្គលតំណាងបុគ្គលចុះបញ្ជីលក់មូលបត្រ | **បណ្ឌិត អ៊ិន ចាន់នី** |

## ខ- លក្ខណៈនៃធុរកិច្ច

ធនាគារ អេស៊ីលីដា ភីអិលស៊ី គឺជាធនាគារពាណិជ្ជដែលមានសាខា និងបណ្តាញការិយាល័យធំជាងគេបង្អស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ធនាគារបានចុះបញ្ជីនៅផ្សារមូលបត្រកម្ពុជា (ផមក) ចាប់តាំងពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០។ បច្ចុប្បន្ននេះ ធនាគារមានក្រុមហ៊ុនបុត្រសម្ព័ន្ធចំនួន៤ រួមមាន៖ (១) ធនាគារ អេស៊ីលីដា ឡាវ លីមីតធីត (២) ស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា (៣) ក្រុមហ៊ុន អេស៊ីលីដា ស៊ីឃ្យួរីធី ភីអិលស៊ី និង (៤) វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ព្រមទាំងមានការិយាល័យតំណាងចំនួន១នៅប្រទេសមីយ៉ាន់ម៉ា។

## គ- ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ

- នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣ ធនាគារបានទទួលវិញ្ញាបនបត្រឧត្តមភាពអាជីវកម្មក្នុងវិស័យធនាគារ និងពានរង្វាន់ឧត្តមភាពអាជីវកម្ម សម្រាប់ឆ្នាំ២០២៣ ពីស្ថានកុងស៊ុលកិត្តិយសកម្ពុជា។
- នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២៣ ធនាគារ បានទទួលលិខិតថ្លែងអំណរគុណ ពីក្រសួងព័ត៌មាន ដែលធនាគារបានឧបត្ថម្ភថវិកាក្នុងមូលនិធិ ដើម្បីជួយដល់មន្ទីរពេទ្យគន្ធបុប្ផាកម្ពុជា និងអង្គការគ្រួសារថ្មី ដែលជាការងារមនុស្សធម៌មួយក្នុងការរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីកាត់បន្ថយភាពក្រីក្រ។

- នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣ ធនាគារ បានទទួលប័ណ្ណថ្លែងអំណរគុណពីកាកបាទក្រហមកម្ពុជា សម្រាប់ការឧបត្ថម្ភថវិកាចំនួន៨០០លានរៀល ក្នុងពិធីអបអរខួបទី១៦០ ទិវាពិភពលោកកាកបាទក្រហម និងអឌ្ឍចន្ទក្រហមថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២៣ ក្រោមប្រធានបទ **"រួមគ្នាជាមួយកាកបាទក្រហមកម្ពុជា ដើម្បីបរិយាបន្នសង្គម"**។
- នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣ ធនាគារ បានទទួលវិញ្ញាបនបត្របញ្ជាក់សមាជិកភាព របស់ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា។ តាមរយៈវិញ្ញាបនបត្រនេះ ធនាគារបានក្លាយជាសមាជិកផ្លូវការរបស់ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា។ ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (Cambodia Data Exchange/CamDX) ឬហៅកាត់ថា ថ.ផ.ទ. ជាថ្នាលបច្ចេកវិទ្យាព័ត៌មានរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលត្រូវបានដាក់ឱ្យដំណើរការដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលត្រូវបានបង្កើតឡើងសម្រាប់ផ្លាស់ប្តូរទិន្នន័យដោយប្រើប្រាស់សន្ទានកម្មនៃកម្មវិធីកុំព្យូទ័រ (Application Programming Interface-API) រវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយ និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយទៀតក្នុងវិស័យសាធារណៈ និងជាមួយវិស័យឯកជន ដែលជាសមាជិក ថ.ផ.ទ. ដោយសុវត្ថិភាពតាមរយៈប្រព័ន្ធអ៊ីនធឺណែត ឬបណ្តាញតភ្ជាប់ឌីជីថលផ្សេងៗ។
- នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣ ធនាគារ បានទទួលប័ណ្ណសរសើរពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលធនាគារបានប្រកាស និងបង់ពន្ធលើប្រាក់ចំណូលជូនរដ្ឋជាប់លំដាប់ទី៤ ក្នុងចំណោមសហគ្រាសដែលបង់ពន្ធច្រើនជាងគេ ក្នុងឆ្នាំ២០២២។
- នៅថ្ងៃទី១ ខែឧសភា ឆ្នាំ២០២៣ ធនាគារ បានទទួលលិខិតថ្លែងអំណរគុណ ពីបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) ដែលធនាគារ បានឧបត្ថម្ភថវិកាក្នុងកម្មវិធី "សមាជិក ប.ស.ស. ឆ្នើម ២០២៣"។
- នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៣ ធនាគារ បានទទួលពានរង្វាន់ដៃគូទូទាត់ និងបម្រើអតិថិជនល្អឥតខ្ចោះ ឆ្នាំ២០២១-២០២២ ពីធនាគារ Wells Fargo។
- នៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៣ **ធនាគារជាតិ នៃកម្ពុជា និងធនាគារជាតិថៃ** បានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ សេវាទូទាត់ឆ្លងដែនរវាងកម្ពុជា និងថៃ ដំណាក់កាលទី២ ដែលអនុញ្ញាតឱ្យ ជនជាតិថៃ ដែលធ្វើដំណើរមកប្រទេសកម្ពុជា អាចស្កេនទូទាត់ទិញទំនិញ ឬសេវាកម្មផ្សេងៗ តាមរយៈ QR បានដូចគ្នានឹងជនជាតិខ្មែរ ដែលធ្វើដំណើរទៅកាន់ប្រទេសថៃដែរ។ កម្រៃសេវាសម្រាប់ប្រតិបត្តិការស្កេនទូទាត់ឆ្លងដែន រវាងប្រទេសទាំងពីរ គឺមិនគិតថ្លៃសេវាឡើយ។ ធនាគារ អេស៊ីលីដា ជាធនាគារទំនាក់ទំនង ដូច្នេះអ្នកប្រើប្រាស់**អេស៊ីលីដាម៉ូបាល** អាច**ស្កេន QR** ទូទាត់ថ្លៃទំនិញ និងសេវាកម្មផ្សេងៗ ជាប្រាក់រៀល នៅក្នុង**ប្រទេសថៃ**បានជាមួយពាណិជ្ជករ (អ្នកលក់) ដែលមានស្លាកសញ្ញា **ThaiQR/PromptPay** របស់ធនាគារចំនួនប្រាំនៅប្រទេសថៃ មានដូចជា៖ **Kasikorn Bank, KrungThai Bank, Bangkok Bank, Bank of Ayudhya** និង **Siam Commercial Bank** ក្នុងចំនួនទឹកប្រាក់រហូតដល់ទៅ **៥២លានរៀល ក្នុងមួយថ្ងៃ** (កាត់ពីគណនីវ៉លឡេត៖ **១២លានរៀល** និងគណនីធនាគារ៖ **៤០លានរៀល**)។
- នៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២៣ ធនាគារ បានចុះកិច្ចព្រមព្រៀងជាមួយ ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី (ស៊ីប៊ីស៊ី) ជាក្រុមហ៊ុនឈានមុខគេក្នុងការផ្តល់នូវសេវាចែករំលែកព័ត៌មានឥណទាននៅកម្ពុជា ក្នុងគោលបំណងដើម្បីដាក់ឱ្យដំណើរការ**សេវាពិនិត្យសុខភាពហិរញ្ញវត្ថុ** លើកម្មវិធីទូរស័ព្ទ **អេស៊ីលីដាម៉ូបាល** ដែលជាមធ្យោបាយកាន់តែងាយស្រួល និងលឿនឆាប់រហ័សជាងមុន សម្រាប់អតិថិជនអាចស្នើសុំរបាយការណ៍ឥណទានរបស់ពួកគាត់ បានគ្រប់ពេលវេលា គ្រប់ទីកន្លែង ជាមួយនឹងថ្លៃសេវាសមរម្យ។ **មុខងាររបស់ស៊ីប៊ីស៊ី** ដែលមាននៅក្នុង**អេស៊ីលីដាម៉ូបាល** នឹងបង្ហាញប្រវត្តិនៃការខ្ចីប្រាក់ និងការទូទាត់សងប្រាក់របស់អតិថិជន ជាមួយនឹងធនាគារ អេស៊ីលីដា ឬគ្រឹះស្ថានធនាគារ និងស្ថាប័នហិរញ្ញវត្ថុដទៃទៀត។
- នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៣ ធនាគារ បានសហការជាមួយស្ថាប័ន **Global Loyalty Network** "GLN International Inc." ដែលជាក្រុមហ៊ុនបណ្តាញឌីជីថលសកល សម្រាប់ទូទាត់ឆ្លងដែន តាមរយៈទូរស័ព្ទចល័ត។ សមិទ្ធផលនេះនឹងអនុញ្ញាតឱ្យអ្នកប្រើប្រាស់ទូរស័ព្ទចល័តនៅក្នុងបណ្តាញ GLN មកពីសាធារណរដ្ឋកូរ៉េ និងនៅជុំវិញពិភពលោក អាចទូទាត់ថ្លៃទំនិញ និង

សេវាកម្មផ្សេងៗ នៅក្នុងប្រទេសកម្ពុជា តាមរយៈទូរស័ព្ទចល័ត ដោយគ្រាន់តែបង្ហាញនូវឃ្យូអរកូដ ដើម្បីស្កេនជាមួយម៉ាស៊ីន POS បានកាន់តែមានភាពងាយស្រួល រហ័ស សុវត្ថិភាព និងសម្បូរបែប។

# ផ្នែកទី២- ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

## ក- លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក

- **ប្រតិបត្តិការក្នុងវិស័យធនាគារ**

ត្រឹមដំណាច់ខែមិថុនា ឆ្នាំ២០២៣ ធនាគារពាណិជ្ជមានចំនួន៥៩ (ធនាគារក្នុងស្រុកចំនួន៣០ បុត្រសម្ព័ន្ធធនាគារបរទេសចំនួន ១៨ និងសាខាធនាគារបរទេសចំនួន១១) ធនាគារឯកទេសចំនួន០៩ (ធនាគារក្នុងស្រុកចំនួន០៤ និងធនាគារបរទេសចំនួន០៥) គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន៨៧ (គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន០៥ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើចំនួន៨២) ក្រុមហ៊ុនភតិសន្យាចំនួន១៧ ការិយាល័យតំណាងធនាគារបរទេសចំនួន០៦ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ចំនួន៣៥ និងគ្រឹះស្ថានឥណទានជនបទចំនួន១១៨។ (Source: NBC Report, CMA Report, Actually Updated)

- **ប្រតិបត្តិការអាជីវកម្ម និងចំណែកទីផ្សាររបស់ធនាគារ អេស៊ីលីដា នៅក្នុងវិស័យធនាគារ**

គិតត្រឹមដំណាច់ខែមិថុនា ឆ្នាំ២០២៣ ធនាគារ អេស៊ីលីដា ភីអិលស៊ី មានចំណែកទីផ្សារសម្រាប់ប្រាក់បញ្ញើសន្សំចំនួន ១៥,៨៤% និងសម្រាប់ឥណទានចំនួន ១១,៣៩%។

គិតត្រឹមដំណាច់ខែមិថុនា ឆ្នាំ២០២៣ ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួនទទួលបានលទ្ធផលសំខាន់ៗ ដូចខាងក្រោម៖

| លទ្ធផលសំខាន់ៗ | លទ្ធផលសម្រេចបាន | | |
|---|---|---|---|
| | ត្រីមាសទី២ ឆ្នាំ២០២៣ | ឆ្នាំ២០២២ | ឆ្នាំ២០២១ |
| **សេវាឥណទាន** | | | |
| ចំនួនឥណទានសកម្ម | ៦២៥.៦៥៩ | ៥៩១.៩៩៤ | ៥៤១.១៨៤ |
| សមតុល្យឥណទានសរុប (លានរៀល) | ២៧.០៤១.៧១៦ | ២៦.៤៣៧.៩២៨ | ២២.១១៦.០១៣ |
| **សេវាបញ្ញើ-សន្សំ** | | | |
| ចំនួនគណនីសរុប | ៤.២៣៩.១៤៨ | ៣.៨៦៥.៧៤៩ | ៣.២៩៨.៣៨២ |
| សមតុល្យប្រាក់បញ្ញើសរុប (លានរៀល) | ២៨.៤៨៦.៣២០ | ២៦.៣០៣.៤៧៥ | ២៣.២៨៧.០៦៤ |
| **សេវាធនាគារអេឡិចត្រូនិក** | | | |
| **ប័ណ្ណអេធីអឹមអេស៊ីលីដា** | | | |
| ចំនួនប័ណ្ណបោះផ្សាយសរុប | ១.៨៩៤.៦២៤ | ១.៧៩៩.៩០៩ | ១.៥៨៥.៤៤៩ |
| ចំនួនប្រតិបត្តិការសរុប | ១០.០៦៣.៥៨៤ | ២១.០៥៨.៦០៩ | ១៩.៤៤៨.៨៣៧ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៨.៨៤៥.១៦៤ | ១៨.៦៨៣.៣៣៥ | ១៦.១៧៣.៩៩០ |
| **អេស៊ីលីដាម៉ូបាល** | | | |
| ចំនួនអ្នកប្រើប្រាស់សរុប | ៣.១១០.០៤៩ | ២.៨៤៥.៨៨៦ | ២.២៧៨.២២០ |
| ចំនួនប្រតិបត្តិការសរុប | ១៤៨.៨៣៥.៣០៩ | ១៤៨.៧៩៩.៦៦១ | ៧៨.៧២៦.៨៩៥ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ១៧៥.៨១៥.៧១១ | ២០៦.៦៦០.២៦២ | ១១៥.២៤២.៦៣៨ |

| លទ្ធផលសំខាន់ៗ | លទ្ធផលសម្រេចបាន | | |
|---|---|---|---|
| | ត្រីមាសទី២ ឆ្នាំ២០២៣ | ឆ្នាំ២០២២ | ឆ្នាំ២០២១ |
| **អេស៊ីលីដាអ៊ីនធើណែត** | | | |
| ចំនួនអ្នកប្រើប្រាស់សរុប | ២៣.៦៩៣ | ២២.១៦៤ | ១៣.៥៥៧ |
| ចំនួនប្រតិបត្តិការសរុប | ១.៦០៣.៣១២ | ២.៣១៨.៧៨៩ | ១.៤៦៦.៤២២ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ១៣.០៧២.៤៦២ | ២៦.១៥៨.៧០៥ | ១៩.៧៩៩.៤៦៤ |
| **អេស៊ីលីដាអ៊ីខុមមើស** | | | |
| ចំនួនដៃគូអាជីវកម្មសរុប | ៨៤ | ៧៣ | ៥៩ |
| ចំនួនប្រតិបត្តិការសរុប | ២.០១១.៥១៣ | ៣.៦១៩.៩៣៦ | ៣.២១៥.២០៧ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ១.១៩៨.៣៤១ | ១.៨០៤.១៣៦ | ១.២០៦.៥២៩ |
| **ម៉ាស៊ីនអេធីអឹមអេស៊ីលីដា** | | | |
| ចំនួនម៉ាស៊ីនសរុប | ១.១៦៧ | ១.១១៤ | ៩០១ |
| ចំនួនប្រតិបត្តិការសរុប | ១៩.៦៥៤.១១០ | ៣៥.២៩៨.២១៤ | ២៧.១២៩.២៥២ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ២២.០២៦.៣៣០ | ៣៩.១៦០.៩៧៦ | ២៦.៤៧៧.៣៤១ |
| **ម៉ាស៊ីនដាក់ប្រាក់បញ្ញើមានកាលកំណត់** | | | |
| ចំនួនម៉ាស៊ីនសរុប | ២៦ | ២៦ | ២៦ |
| ចំនួនប្រតិបត្តិការសរុប | ១៩៧ | ១.៤៨៧ | ៤.១២០ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៦.៦០៨ | ១១១.១៣៤ | ៣៨៣.១៥៨ |
| **ម៉ាស៊ីនបើកគណនី និងបោះពុម្ពប័ណ្ណអេធីអឹម** | | | |
| ចំនួនម៉ាស៊ីនសរុប | ៩៦ | ៤៣ | ២៥ |
| ចំនួនប្រតិបត្តិការសរុប | ៥៧.២៨៨ | ៤៣.០៨៩ | ៣៤.០៩២ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៣ | ១៦ | ៧០ |
| **ម៉ាស៊ីនទទួលកាបូបប្រាក់** | | | |
| ចំនួនម៉ាស៊ីនសរុប | ១៧ | ១៧ | ១៤ |
| ចំនួនប្រតិបត្តិការសរុប | ៤៤.៨៦៧ | ៧៥.០២០ | ៩៤.៧១៣ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ២៧២.៤១៧ | ៥៧១.០៩៨ | ៥៥៥.២៥៧ |
| **ម៉ាស៊ីនឆូតកាតអេស៊ីលីដា** | | | |
| ចំនួនម៉ាស៊ីនឆូតកាតសរុប | ៤.២១០ | ៤.៣៥៨ | ៤.៤៦២ |
| ចំនួនប្រតិបត្តិការសរុប | ៩៩០.១៣៦ | ២.១៥៩.១៧៥ | ២.០៣៣.២៨៣ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៣១៤.៤៥៧ | ៥៩១.៦០៣ | ៤៧៩.៦១៣ |

| លទ្ធផលសំខាន់ៗ | លទ្ធផលសម្រេចបាន | | |
| --- | --- | --- | --- |
| | ត្រីមាសទី២ ឆ្នាំ២០២៣ | ឆ្នាំ២០២២ | ឆ្នាំ២០២១ |
| **ឃ្យូអរ ពាណិជ្ជករ** | | | |
| ចំនួនពាណិជ្ជករ | ៣១៦.៦១២ | ២៣៩.៧៥១ | ១២៥.៣០៩ |
| ចំនួនប្រតិបត្តិការសរុប | ៣៩.៣០៤.៨៧៥ | ១៦.៤៥៩.៣៧៧ | ៣.១៩៤.៤៤៣ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ២៧.៤៧៣.៨៥៤ | ៧.៧៧៧.៤៩១ | ៦៣៨.២៤០ |
| **ប័ណ្ណនិម្មិតអេស៊ីលីដា** | | | |
| ចំនួនប័ណ្ណនិម្មិត | ១៦.៩៧៩ | ៨.៨៩៨ | ៣.៦៨៤ |
| ចំនួនប្រតិបត្តិការសរុប | ៤៨.៥៣៩ | ៣៤.៩០៧ | ២.៤៩១ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៥.៦៨៧ | ៣.០១៨ | ១៦១ |
| **ខ្សែអាយប៊ែង** | | | |
| ចំនួនខ្សែបោះផ្សាយសរុប | ១០.៥៧៨ | ៤.៩៦០ | - |
| ចំនួនប្រតិបត្តិការសរុប | ៨.២៣៥ | ១៨.៧៤២ | - |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៩.០១៨ | ៣១.៧៦២ | - |
| **បណ្ដាញប្រតិបត្តិការ និង បុគ្គលិក** | | | |
| **ធនាគារ អេស៊ីលីដា ភីអិលស៊ី** | | | |
| ចំនួនការិយាល័យសរុប | ២៦៤ | ២៦៤ | ២៦២ |
| ចំនួនធនាគារស្វ័យប្រវត្តិ | ១៤៨ | ១២៥ | ៧៣ |
| ចំនួនបុគ្គលិកសរុប | ១២.០៦៥ | ១២.០៨៣ | ១២.០៨១ |
| **ក្រុមហ៊ុនបុត្រសម្ព័ន្ធ (ក្នុង និង ក្រៅប្រទេស)** | | | |
| ចំនួនការិយាល័យសរុប | ៥៦ | ៥៦ | ៥៧ |
| ចំនួនបុគ្គលិកសរុប | ១.៥១០ | ១.៤៩៩ | ១.៥៩៣ |

## ខ- រចនាសម្ព័ន្ធចំណូល

| ល.រ | ប្រភពចំណូល (លានរៀល) | ត្រីមាសទី២ ឆ្នាំ២០២៣ | | ត្រីមាសទី២ ឆ្នាំ២០២២ | | ត្រីមាសទី២ ឆ្នាំ២០២១ | |
|---|---|---|---|---|---|---|---|
| | | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ១ | ចំណូលការប្រាក់ | ៧៧១.៩២៤ | ៩១,៤៤% | ៦៦៩.៤៣២ | ៨៩,០១% | ៥៧០.១២៦ | ៩១,១៤% |
| ២ | ចំណូលកម្រៃនិងជើងសា | ៤៧.១១៩ | ៥,៥៨% | ៤៩.៣៤៨ | ៦,៥៦% | ៣៨.៤៣០ | ៦,១៤% |
| ៣ | ចំណូលផ្សេងៗសុទ្ធ | ២៥.១៨៥ | ២,៩៨% | ៣៣.២៨៧ | ៤,៤៣% | ១៦.៩៦១ | ២,៧១% |
| **ចំណូលសរុប** | | **៨៤៤.២២៨** | **១០០%** | **៧៥២.០៦៧** | **១០០%** | **៦២៥.៥១៧** | **១០០%** |

# ផ្នែកទី៣- របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មដោយសវនករឯករាជ្យ

សូមពិនិត្យមើលឧបសម្ព័ន្ធដែលបានភ្ជាប់មកជាមួយ
របាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានធ្វើសវនកម្មដោយសវនករឯករាជ្យ

## ផ្នែកទី៤- ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

ការពិភាក្សា និងការវិភាគខាងក្រោមនេះផ្តោតសំខាន់លើលទ្ធផលប្រតិបត្តិការ និងលទ្ធផលហិរញ្ញវត្ថុដោយផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុចន្លោះពេលគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ ដែលត្រូវបានធ្វើសវនកម្មដោយសវនករឯករាជ្យ។ របាយការណ៍ហិរញ្ញវត្ថុចន្លោះពេលត្រូវបានរៀបចំឡើងដោយអនុលោមតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (“ស.រ.ទ.ហ.អ.ក”)។ មានតែសមាសធាតុសំខាន់ៗនៃរបាយការណ៍ហិរញ្ញវត្ថុចន្លោះពេល និងកត្តាសំខាន់ៗដែលប៉ះពាល់ដល់ប្រាក់ចំណេញរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ធនាគារ (“សម្ព័ន្ធធនាគារ”) ប៉ុណ្ណោះ ត្រូវបានយកមកធ្វើការពិភាក្សា និងវិភាគ។

## ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

### ១- ការវិភាគចំណូល

សម្ព័ន្ធធនាគារ មានប្រភពចំណូលធំៗចំនួនបីគឺ ចំណូលការប្រាក់ ចំណូលកម្រៃនិងជើងសា និងចំណូលផ្សេងៗសុទ្ធ។

- ចំណូលការប្រាក់៖ រួមមានចំណូលការប្រាក់ពីឥណទាននិងបុរេប្រទាន ចំណូលការប្រាក់ពីប្រាក់បញ្ញើនៅធនាគារផ្សេងៗ និងការវិនិយោគហិរញ្ញវត្ថុ។
- ចំណូលកម្រៃនិងជើងសា៖ រួមមានកម្រៃជើងសា កម្រៃជើងសាបានពីភ្នាក់ងារធានារ៉ាប់រង កម្រៃពីម៉ាស៊ីនអេធីអឹម កម្រៃពីការសងឥណទានមុនកាលកំណត់ កម្រៃពីសេវាប្រាក់បញ្ញើ កម្រៃពីសេវាធានា និងកម្រៃពីការបណ្តុះបណ្តាល។
- ចំណូលផ្សេងៗសុទ្ធ៖ រួមមានចំណេញពីការប្តូររូបិយប័ណ្ណ-សុទ្ធ ចំណេញពីការលក់ទ្រព្យនិងបរិក្ខារ ភាគលាភលើការវិនិយោគហិរញ្ញវត្ថុ និងចំណូលផ្សេងៗ។

### ២- ការវិភាគចំណូលតាមផ្នែក

| ល.រ | ប្រភពចំណូល (លានរៀល) | ត្រីមាសទី២ ឆ្នាំ២០២៣ | | ត្រីមាសទី២ ឆ្នាំ២០២២ | | ត្រីមាសទី២ ឆ្នាំ២០២១ | |
|---|---|---|---|---|---|---|---|
| | | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ១ | ចំណូលការប្រាក់ | ៧៧១.៩២៤ | ៩១,៤៨% | ៦៦៩.៤៣២ | ៨៩,០១% | ៥៧០.១២៦ | ៩១,១៤% |
| ២ | ចំណូលកម្រៃនិងជើងសា | ៤៧.១១៩ | ៥,៥៨% | ៤៩.៣៤៨ | ៦,៥៦% | ៣៨.៤៣០ | ៦,១៤% |
| ៣ | ចំណូលផ្សេងៗសុទ្ធ | ២៥.១៨៥ | ២,៩៨% | ៣៣.២៨៧ | ៤,៤៣% | ១៦.៩៦១ | ២,៧១% |
| | **ចំណូលសរុប** | **៨៤៤.២២៨** | **១០០%** | **៧៥២.០៦៧** | **១០០%** | **៦២៥.៥១៧** | **១០០%** |

ចំណូលសរុបនៅត្រីមាសទី២ ឆ្នាំ២០២៣ បានកើនឡើងចំនួន ៩២,១៦ ប៊ីលានរៀល ឬ ១២,២៥% បើប្រៀបធៀបទៅនឹងត្រីមាសទី២ ឆ្នាំ២០២២ ដែលការកើនឡើងទាំងនេះគឺដោយសារប្រសិទ្ធភាពនៃផលិតផលនិងសេវាកម្មដ៏សម្បូរបែបរបស់ធនាគារក្នុងយុគសម័យឌីជីថល និងកំណើនអតិថិជន។

### ៣- ការវិភាគគម្លាតចំណេញដុល

របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗរបស់សម្ព័ន្ធធនាគារ បានរៀបចំក្នុងទម្រង់ជារបាយការណ៍ដែលមិនបង្ហាញពីគម្លាតចំណេញដុលទេ។ ចំណូលការប្រាក់សុទ្ធដែលទទួលបានមកពីចំណូលការប្រាក់សរុបដកនឹងចំណាយការប្រាក់សរុបនឹងត្រូវយកមកបង្ហាញនៅក្នុងការវិភាគចំណេញ/(ខាត) មុនបង់ពន្ធ ដូចខាងក្រោម។

## ៤- ការវិភាគចំណេញ/(ខាត) មុនបង់ពន្ធ

| របាយការណ៍ចំណេញ ឬខាត (លានរៀល) | ត្រីមាសទី២ ឆ្នាំ២០២៣ | ត្រីមាសទី២ ឆ្នាំ២០២២ | គម្លាត | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| ចំណូលការប្រាក់ | ៧៧១.៩២៤ | ៦៦៩.៤៣២ | ១០២.៤៩២ | ១៥,៣១% |
| ចំណាយការប្រាក់ | (៣៤០.៧០១) | (២០៥.៣៦៩) | (១៣៥.៣៣២) | ៦៥,៩០% |
| **ចំណូលការប្រាក់សុទ្ធ** | **៤៣១.២២៤** | **៤៦៤.០៦៣** | **(៣២.៨៣៩)** | **(៧,០៨%)** |
| ចំណូលកម្រៃនិងជើងសា | ៤៧.១១៩ | ៤៩.៣៤៨ | (២.២២៩) | (៤,៥២%) |
| ចំណាយកម្រៃនិងជើងសា | (៤.៤៧៦) | (៣.៩៧៨) | (៤៩៨) | ១២,៥២% |
| **ចំណូលកម្រៃនិងជើងសាសុទ្ធ** | **៤២.៦៤២** | **៤៥.៣៧០** | **(២.៧២៨)** | **(៦,០១%)** |
| សំវិធានធននៃការខាតបង់ឱនភាពនៃតម្លៃរបស់ឥណទាននិងបុរេប្រទាន ប្រាក់បញ្ញើនៅធនាគារផ្សេងៗគណនីត្រូវទទួល និងមូលបត្រវិនិយោគផ្សេងៗ | (៥៣.៩៧៧) | (៨.៦៣៧) | (៤៥.៣៤០) | ៥២៤,៩៥% |
| (សំវិធានធន)/ការកត់ត្រាត្រឡប់នៃការខាតបង់ឱនភាពនៃតម្លៃកិច្ចសន្យាក្រៅតារាងតុល្យការ | ២ | (២) | ៤ | (២០០%) |
| **ចំណាយពីការខាតបង់ឱនភាពនៃតម្លៃសុទ្ធ** | **(៥៣.៩៧៥)** | **(៨.៦៣៩)** | **(៤៥.៣៣៦)** | **៥២៤,៧៨%** |
| **ចំណូលបន្ទាប់ពីការខាតបង់ឱនភាពនៃតម្លៃ** | **៤១៩.៨៩១** | **៥០០.៧៩៤** | **(៨០.៩០៣)** | **(១៦,១៥%)** |
| ចំណូលផ្សេងៗសុទ្ធ | ២៥.១៨៥ | ៣៣.២៨៧ | (៨.១០២) | (២៤,៣៤%) |
| ចំណាយទូទៅនិងរដ្ឋបាល | (២៧១.៥៧០) | (២៨៤.៥៦៤) | ១២.៩៩៤ | (៤,៥៧%) |
| **ចំណេញមុនចំណាយពន្ធលើប្រាក់ចំណេញ** | **១៧៣.៥០៦** | **២៤៩.៥១៦** | **(៧៦.០១០)** | **(៣០,៤៦%)** |

ការកើនឡើងនូវភាពជឿជាក់របស់អតិថិជនមកលើសម្ព័ន្ធធនាគារ ធ្វើឱ្យប្រាក់បញ្ញើនៅដំណាច់ខែមិថុនា ឆ្នាំ២០២៣ កើនឡើងដល់ ២៨,៤៩ ទ្រីលានរៀល ដែលបានកើនឡើងចំនួន ៤,០៤ ទ្រីលានរៀល ឬ ១៦,៥៥% ពីដំណាច់ខែមិថុនា ឆ្នាំ២០២២។ ដោយអនុវត្តតាមបទប្បញ្ញត្តិទាក់ទងនឹងការធ្វើចំណាត់ថ្នាក់ឥណទាន និងដើម្បីភាពរឹងមាំ និងការទប់ទល់រាល់ហានិភ័យ ដែលអាចជះឥទ្ធិពលដល់ឥណទាននិងបុរេប្រទានដល់អតិថិជន ជាពិសេសហានិភ័យដែលអាចកើតចេញពីកូវីដ-១៩ ធនាគារបានបង្កើននូវការខាតបង់ឥណទានរំពឹងទុក និងបុរេប្រទានចំនួន ៣១,៨៤ ប៊ីលានរៀល បន្ថែមទៀត ធៀបនឹងដំណាច់ខែមីនា ឆ្នាំ២០២៣។

## ៥- ការវិភាគចំណេញ/(ខាត) ក្នុងការិយបរិច្ឆេទ

| របាយការណ៍ចំណេញ ឬខាត (លានរៀល) | ត្រីមាសទី២ ឆ្នាំ២០២៣ | ត្រីមាសទី២ ឆ្នាំ២០២២ | គម្លាត | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| **ចំណេញមុនចំណាយពន្ធលើប្រាក់ចំណេញ** | **១៧៣.៥០៦** | **២៤៩.៥១៦** | **(៧៦.០១០)** | **(៣០,៤៦%)** |
| ចំណាយពន្ធលើប្រាក់ចំណេញ | (៣៧.៩៣២) | (៥៣.៦៥១) | ១៥.៧១៩ | (២៩,៣០%) |
| **ប្រាក់ចំណេញក្នុងការិយបរិច្ឆេទ** | **១៣៥.៥៧៤** | **១៩៥.៨៦៥** | **(៦០.២៩១)** | **(៣០,៧៨%)** |

## ៦- ការវិភាគលទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ

| លទ្ធផលលម្អិតសរុប (លានរៀល) | ត្រីមាសទី២ ឆ្នាំ២០២៣ | ត្រីមាសទី២ ឆ្នាំ២០២២ | គម្លាត | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| **ប្រាក់ចំណេញក្នុងការិយបរិច្ឆេទ** | **១៣៥.៥៧៤** | **១៩៥.៨៦៥** | **(៦០.២៩១)** | **(៣០,៧៨%)** |
| **លទ្ធផលលម្អិតផ្សេងៗ៖** | | | | |
| ***ធាតុដែលនឹងមិនត្រូវបានចាត់ថ្នាក់ឡើងវិញទៅចំណេញ ឬខាត៖*** | | | | |
| ការវាស់វែងឡើងវិញនៃកាតព្វកិច្ចអត្ថប្រយោជន៍និយោជិត | - | (១០.៤៣៦) | ១០.៤៣៦ | ១០០% |
| លម្អៀងពីអត្រាប្តូរប្រាក់ | ១០០.៤១២ | ១៩៩ | ១០០.២១៣ | ៥០.៣៥៨,២៩% |
| ***ធាតុដែលត្រូវ ឬអាចត្រូវបានចាត់ថ្នាក់ឡើងវិញនៅគ្រាបន្ទាប់ទៅចំណេញ ឬខាត៖*** | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ-ក្រុមហ៊ុនបុត្រសម្ព័ន្ធបរទេស | (១៧.៥៨៣) | (៣៩.១៤១) | ២១.៥៥៨ | ៥៥,០៨% |
| ការវាស់វែងឡើងវិញលើផ្នែកដែលមានប្រសិទ្ធភាពរបស់ឧបករណ៍និស្សន្ទដែលកើតឡើងពីការការពារហានិភ័យលំហូរសាច់ប្រាក់ | (១.១២១) | ៨.២០៤ | (៩.៣២៥) | (១១៣,៦៦%) |
| **លទ្ធផលលម្អិតផ្សេងៗក្នុងការិយបរិច្ឆេទ** | **៨១.៧០៨** | **(៤១.១៧៤)** | **១២២.៨៨២** | **២៩៨,៤៥%** |
| **លទ្ធផលលម្អិតសរុបក្នុងការិយបរិច្ឆេទ** | **២១៧.២៨២** | **១៥៤.៦៩១** | **៦២.៥៩១** | **៤០,៤៦%** |

## ៧- ការវិភាគពីកត្តា និងនិន្នាការដែលប៉ះពាល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ

ធនាគារ អេស៊ីលីដា មានទំនុកចិត្តក្នុងការធ្វើឱ្យប្រសើរឡើងនូវប្រតិបត្តិការរបស់ខ្លួន ចំពេលការព្យាករកំណើនសេដ្ឋកិច្ចមានសញ្ញាល្អប្រសើរឡើង បន្ទាប់ពីបានកសាងកេរ្តិ៍ដំណែលដ៏រឹងមាំអស់រយៈពេល ៣០ឆ្នាំកន្លងមកនេះ ធនាគារ អេស៊ីលីដា បានត្រៀមខ្លួនរួចជាស្រេចសម្រាប់ពេលអនាគត ហើយនឹងនៅតែបន្តចាក់គ្រឹះឱ្យកាន់តែរឹងមាំដើម្បីផ្តល់ជូននូវដំណោះស្រាយក្នុងវិស័យធនាគារឱ្យកាន់តែសម្បូរបែប ដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរតម្រូវការផ្នែកហិរញ្ញវត្ថុរបស់អតិថិជនទាំងនៅក្នុង និងក្រៅប្រទេសកម្ពុជា។

បន្ទាប់ពីបំបែកព្រំដែនភូមិសាស្ត្រ ដោយការដាក់បញ្ចូលនូវហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងរូបវន្ត ធនាគារដែលបានបង្កើតឡើងនៅក្នុងស្រុកមួយនេះ កំពុងផ្តល់ជូននូវសេវាកម្មធនាគារសម្រាប់មូលដ្ឋានអតិថិជនចម្រុះដោយជោគជ័យ ដែលមានរាប់ចាប់តាំងពីសេវាធនាគារបុគ្គល និងសម្រាប់សាជីវកម្ម ទាំងនៅក្នុងទីក្រុង រហូតដល់តំបន់ជនបទ។ ជាមួយនឹងភាពលេចធ្លោក្នុងការផ្តល់ជូននូវសេវាកម្មហិរញ្ញវត្ថុដ៏សម្បូរបែប ដូចជាផ្តល់ប្រាក់កម្ចី ផ្ទេរប្រាក់ ប្រាក់បញ្ញើ ហិរញ្ញប្បទានពាណិជ្ជកម្ម អេស៊ីលីដាអ៊ីនធើណែត **អេស៊ីលីដា ម៉ូបាល** និងសេវាសំខាន់ជាច្រើនទៀត គាំទ្រដោយហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងការិយាល័យរូបវន្តរបស់ខ្លួន ធនាគារ អេស៊ីលីដា កំពុងចូលរួមយ៉ាងសកម្មក្នុងការជួយដល់កសិករ តាមរយៈការផ្តល់ដើមទុនសម្រាប់ធ្វើស្រែចម្ការរបស់គាត់ ឬផ្តល់ទុនសម្រាប់សហគ្រាសធុនតូច និងមធ្យមជាដើម។ តាមរយៈការបង្រួមគម្លាតចំពោះការទទួលបានហិរញ្ញប្បទាន សព្វថ្ងៃនេះប្រជាជនកម្ពុជាច្រើនជាងកន្លះលាននាក់ មានលទ្ធភាពប្រើប្រាស់សេវារបស់ធនាគារ អេស៊ីលីដា ដែលជាការជំរុញនិងលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុនៅព្រះរាជាណាចក្រកម្ពុជា។

សម្រាប់រយៈពេល៣០ឆ្នាំខាងមុខ គេនឹងមើលឃើញ ធនាគារ អេស៊ីលីដា គឺជាធនាគារឌីជីថល ដែលមានរិស្វកម្មគ្រប់គ្រងទិន្នន័យទំនើបទាន់សម័យ (Data Lakehouse) ប្រកបដោយគុណភាព សុវត្ថិភាព និងទំនុកចិត្ត។ ប្រព័ន្ធអេកូនៃបណ្តាញប្រកបដោយប្រសិទ្ធភាពរបស់ធនាគារនៅទូទាំងប្រទេស រួមមានម៉ាស៊ីន ATM ទីតាំងធនាគារស្វ័យប្រវត្តិ ម៉ាស៊ីនដក-ដាក់ប្រាក់ ម៉ាស៊ីនបើកគណនីនិងបោះពុម្ពប័ណ្ណអេធីអឹម ម៉ាស៊ីនដាក់ប្រាក់បញ្ញើមានកាលកំណត់ កំពុងដើរតួជាកាតាលីករដ៏មានឥទ្ធិពលមួយសម្រាប់រលកនៃកំណើនបន្ទាប់។

អនាគតរបស់ធនាគារនឹងកាន់តែរឹងមាំ ខណៈទំនុកចិត្តរបស់អាជីវកម្មលើកំណើនសេដ្ឋកិច្ចរបស់កម្ពុជានឹងកើនឡើង បន្ទាប់ពីរាជរដ្ឋាភិបាលបានទប់ស្កាត់ការរីករាលដាលនៃជំងឺរាតត្បាតកូវីដ-១៩ ប្រកបដោយប្រសិទ្ធភាពខ្ពស់។ ទស្សនៈវិស័យកំណើនរបស់ប្រទេសកម្ពុជា ត្រូវបានរំពឹងថានឹងងើបឡើងវិញនៅពេលដែលការរឹតបន្តឹងបញ្ហាកូវីដ-១៩ ត្រូវបានដកចេញ។

ការងើបឡើងវិញនៃការនាំចេញផ្នែកផលិតកម្ម និងការពង្រីកការនាំចេញទំនិញកសិកម្ម នឹងមានភាពល្អប្រសើរសម្រាប់ធនាគារអេស៊ីលីដា ដោយសារអ្នកទទួលកម្ចីភាគច្រើនមានអាជីវកម្មទាក់ទងនឹងកសិផល។ ធនាគារសម្រេចបានលទ្ធផលកាន់តែល្អប្រសើរនៅក្នុងឆ្នាំ២០២៣ ដោយសារធនាគារបានវិនិយោគយ៉ាងច្រើនទៅលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល សាងសង់មជ្ឈមណ្ឌលទិន្នន័យដ៏ធំមួយ ដែលមានសុវត្ថិភាពខ្ពស់ដើម្បីរក្សាទុកទិន្នន័យ។ ការសាងសង់មជ្ឈមណ្ឌលការពារទិន្នន័យ (Disaster Recovery Data Center) នឹងជួយរក្សាទិន្នន័យនៅក្នុងបរិយាកាសដែលមានការការពារខ្ពស់។ ធនាគារមានទំនុកចិត្តចំពោះពេលអនាគត ជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងផលិតផល-សេវាកម្ម ដែលនឹងកាន់តែមានភាពល្អប្រសើរ។

## ខ- កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

### ១- ការវិភាគពីលក្ខខណ្ឌនៃតម្រូវការ និងការផ្គត់ផ្គង់

សម្ព័ន្ធធនាគារ ទទួលបានជោគជ័យនៅលើទីផ្សារអាស្រ័យដោយកត្តាពីរគឺ៖

- កំណើនសំពៀតឥណទាន ដោយសារតម្រូវការខ្ពស់នៅលើទីផ្សារលើផលិតផលឥណទានរបស់សម្ព័ន្ធធនាគារ ជាពិសេសសហគ្រាសធុនតូច និងមធ្យម។
- កំណើនប្រាក់បញ្ញើ-សន្សំ របស់សម្ព័ន្ធធនាគារ រួមជាមួយផលិតផល និងសេវាកម្មផ្សេងទៀត។

កត្តាទាំងពីរនេះត្រូវបានផ្សារភ្ជាប់ជាមួយនឹងការអភិវឌ្ឍឥតឈប់ឈរនៃប្រព័ន្ធឌីជីថលរបស់សម្ព័ន្ធធនាគារ ដែលផ្តល់ជូនអតិថិជននូវផលិតផល និងសេវាកម្មហិរញ្ញវត្ថុប្រកបដោយភាពច្នៃប្រឌិត និងទាន់សម័យ។

សម្ព័ន្ធធនាគារ បាននិងកំពុងតែអភិវឌ្ឍនូវហេដ្ឋារចនាសម្ព័ន្ធចម្រុះឱ្យកាន់តែទូលំទូលាយសម្រាប់ជាជម្រើសដ៏សម្បូរបែបជាមួយនឹងការិយាល័យទាំង៣២០ តាមរយៈការផ្លាស់ប្តូរបន្តិចម្តងៗទៅជាមជ្ឈមណ្ឌលដែលអាចធ្វើស្វ័យប្រតិបត្តិការដែលមានទីតាំងធនាគារស្វ័យប្រវត្តិចំនួន១៤៨ ព្រមទាំងមាន **ម៉ាស៊ីនអេធីអឹមអេស៊ីលីដា** ចំនួន១.១៦៧ គ្រឿង **ម៉ាស៊ីនដាក់ប្រាក់បញ្ញើមានកាលកំណត់** ចំនួន២៦គ្រឿង **ម៉ាស៊ីនបើកគណនីនិងបោះពុម្ពប័ណ្ណអេធីអឹម** ចំនួន៩៦ គ្រឿង **ម៉ាស៊ីនទទួលកាបូបប្រាក់** ចំនួន១៧ គ្រឿង និង **ម៉ាស៊ីនឆូតកាត**ចំនួន៤.២១០ គ្រឿង។ ចំណុចគួរជាទីមោទនភាពគឺសម្ព័ន្ធធនាគារ បានបោះពុម្ពប័ណ្ណ**អេធីអឹមអេស៊ីលីដា** ចំនួន១,៨៩ លានប័ណ្ណជូនដល់អតិថិជន។ បន្ថែមលើនេះ សម្ព័ន្ធធនាគារ បានផ្តល់ **ខ្សែអាយប៊េង** ច្រើនជាង ១០ពាន់ខ្សែដល់អតិថិជន។ ទន្ទឹមនឹងនេះ **អេស៊ីលីដាម៉ូបាល** បានទទួលប្រជាប្រិយភាពយ៉ាងខ្លាំងដែលចំនួននៃអ្នកចុះឈ្មោះប្រើប្រាស់បានកើនដល់ ៣,១១ លាននាក់ នៅដំណាច់ខែមិថុនា ឆ្នាំ២០២៣នេះ ដែលអាចជួយឱ្យចរាចរសាច់ប្រាក់បានឆាប់រហ័សនៅក្នុងសេដ្ឋកិច្ច។

ការបង្កើនភាពងាយស្រួលដល់អតិថិជន និងពង្រឹងប្រព័ន្ធសុវត្ថិភាពអ៊ិនធើណែត គឺជាចំណុចដែលសម្ព័ន្ធធនាគារ ផ្តោតការយកចិត្តទុកដាក់បំផុត។ ដើម្បីសម្រេចនូវវឌ្ឍនភាពគោលដៅដ៏រឹងមាំទាំងនេះ សម្ព័ន្ធធនាគារ នឹងបន្តលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន តាមរយៈការវិនិយោគលើបច្ចេកវិទ្យាទំនើបចុងក្រោយ ពង្រឹងសមត្ថភាពធនធានមនុស្ស ព្រមទាំងពង្រីកនិងកែលម្អដំណើរការអាជីវកម្ម។ ជាយុទ្ធសាស្ត្រ សម្ព័ន្ធធនាគារកំពុងអភិវឌ្ឍប្រព័ន្ធទូទាត់ដែលអាចឱ្យដៃគូទាំងក្នុង និងក្រៅប្រទេសអាចភ្ជាប់ប្រព័ន្ធនេះដើម្បីបម្រើអតិថិជនទៅវិញទៅមក និងឆ្លងព្រំដែន។ ប្រព័ន្ធនេះមិនត្រឹមតែផ្តល់អត្ថប្រយោជន៍ដោយផ្ទាល់ដល់អតិថិជនដ៏

ឆ្លាតវៃរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដៃគូអាជីវកម្មរបស់ពួកគាត់ផងដែរ។ យើងខ្ញុំទទួលស្គាល់ថាអតិថិជន និងដៃគូអាជីវកម្មទាំងអស់គឺជាបណ្តាញតភ្ជាប់ដ៏មានសារសំខាន់សម្រាប់ពង្រីកសេវាកម្មរបស់សម្ព័ន្ធធនាគារ និងរីកចម្រើនជាមួយគ្នា។

**អេស៊ីលីដាម៉ូបាល** ត្រូវបានកែលម្អយ៉ាងទូលំទូលាយ និងផ្លាស់ប្តូររូបរាងថ្មី កាន់តែទំនើប ងាយស្រួល និងមានសុវត្ថិភាពខ្ពស់ ជាមួយនឹងមុខងារពិសេសៗជាច្រើន។ ឥឡូវនេះ អតិថិជនទាំងអស់អាចធ្វើប្រតិបត្តិការប្រាក់បញ្ញើ-សន្សំ (សំចៃ ចរន្ត និងមានកាលកំណត់) តាមរយៈ **អេស៊ីលីដាម៉ូបាល** បានភ្លាមៗ ថែមទាំងទទួលបានការប្រាក់ខ្ពស់ទៀតផង។

**ខេអេចឃ្យូអរកូត (KHQR Code)** ផ្តល់នូវភាពងាយស្រួលជាងមុនជូនដល់អ្នកប្រើប្រាស់ក្នុងការធ្វើប្រតិបត្តិការទូទាត់ថ្លៃទំនិញ និងសេវាកម្មផ្សេងៗប្រកបដោយប្រសិទ្ធភាព សុវត្ថិភាព និងទំនុកចិត្តខ្ពស់ រវាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ដែលជាសមាជិករបស់កម្មវិធីបាគង (**Bakong App**) ។

ឥឡូវនេះ ជាមួយ**អេស៊ីលីដាម៉ូបាល** ពិតជាងាយស្រួល ដោយលោកអ្នកអាចទូទាត់ផ្សេងៗ តាម QR Code (Scan QR) បានគ្រប់ទីកន្លែង នៅទូទាំងប្រទេសថៃ និងវៀតណាម ដោយឥតគិតថ្លៃសេវា។ នេះជាភាពជោគជ័យថ្មីមួយទៀតរបស់ប្រព័ន្ធបាគង និងធនាគារអេស៊ីលីដា ដែលជាសមាជិករបស់បាគង។

## ២- ការវិភាគពីការឡើងចុះនៃថ្លៃវត្ថុធាតុដើម

ធនាគារ អេស៊ីលីដា ភីអិលស៊ី ប្រតិបត្តិការក្នុងវិស័យសេវាកម្ម ដែលការឡើងចុះនៃថ្លៃវត្ថុធាតុដើមមិនអាចអនុវត្តបានចំពោះធនាគារឡើយ។

## ៣- ការវិភាគលើពន្ធ

ធនាគារ អេស៊ីលីដា ភីអិលស៊ី និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ស្ថិតនៅក្រោមច្បាប់ស្តីពីពន្ធដារនៃប្រទេសនីមួយៗ ដូច្នេះធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធមានកាតព្វកិច្ចបង់ពន្ធតាមការកំណត់របស់អាជ្ញាធរពន្ធដារនីមួយៗ។

ការបង់ពន្ធជូនអគ្គនាយកដ្ឋានពន្ធដារមិនត្រឹមតែជាកាតព្វកិច្ច និងការទទួលបានវិញ្ញាបនបត្រអនុលោមភាពសារពើពន្ធប្រភេទ **"មាស"** ពីអគ្គនាយកដ្ឋានពន្ធដារសម្រាប់ឆ្នាំជាប់ពន្ធ២០២២ ដល់២០២៣ ប៉ុណ្ណោះទេ ប៉ុន្តែជាការចូលរួមចំណែកក្នុងសង្គម និងកំណើនសេដ្ឋកិច្ចផងដែរ។

ចំណូលពន្ធគឺជាប្រភពចំណូលដ៏សំខាន់បំផុតសម្រាប់ប្រទេស។ រដ្ឋាភិបាលប្រមូលពន្ធកាន់តែច្រើន ការចូលរួមវិភាគទានកាន់តែច្រើនដល់ការអភិវឌ្ឍប្រទេស។ ធនាគារ អេស៊ីលីដា ភីអិលស៊ី បានបង់ពន្ធច្រើនជាងគេជាប់ចំណាត់ថ្នាក់លេខ៣ និងបង់ពន្ធលើប្រាក់ចំណូលជាប់ចំណាត់ថ្នាក់លេខ៤ ក្នុងចំណោមសហគ្រាសដែលបានបង់ពន្ធច្រើនជាងគេប្រចាំឆ្នាំ២០២២។ ធនាគារអេស៊ីលីដា ភីអិលស៊ី មានមោទនភាពដែលអាចចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាយើង។

## ៤- ការវិភាគលើធាតុដែលខុសពីធម្មតា និងធាតុវិសាមញ្ញ

សម្ព័ន្ធធនាគារ មិនមានធាតុ ប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលខុសពីធម្មតាជាសារវន្តនោះទេ។ ទោះជាយ៉ាងណាក៏ដោយលក្ខខណ្ឌសេដ្ឋកិច្ចដែលបានរងផលប៉ះពាល់ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ ជាពិសេសវីរុសកូវីដ-១៩ បំប្លែងថ្មី ឆ្លងចូលក្នុងសហគមន៍ អាចជះឥទ្ធិពលដល់សមត្ថភាពសងត្រលប់មកវិញរបស់អតិថិជន ដែលគុណភាពឥណទានរបស់សម្ព័ន្ធធនាគារ អាចរងផលប៉ះពាល់បន្តិចបន្តួច។

# គ- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

ដើម្បីចូលរួមគាំទ្រការរីកលូតលាស់អាជីវកម្មរបស់អតិថិជន សម្ព័ន្ធធនាគារ បានផ្តល់អត្រាការប្រាក់មានភាពប្រកួតប្រជែងខ្លាំងចំពោះការស្នើសុំឥណទានថ្មីគ្រប់ប្រភេទ និងដោយកាន់តែមានភាពងាយស្រួល អតិថិជនទាំងអស់អាចដាក់សំណើសុំឥណទានតាម

រយៈ អេស៊ីលីដាម៉ូបាល។ ជាលទ្ធផល សមតុល្យឥណទានដុលសរុបនៅដំណាច់ត្រីមាសទី២ ឆ្នាំ២០២៣ មានការកើនឡើងចំនួន ២,៦១ ទ្រីលានរៀល ឬ ១០,៦៩% ធៀបនឹងដំណាច់ត្រីមាសទី២ ឆ្នាំ២០២២។

## ឃ- ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

នៅត្រីមាសទី២ ឆ្នាំ២០២៣នេះ អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិកបានប្រែប្រួលនៅចន្លោះពី ៤.០៧១រៀល ទៅ ៤.១២៦ រៀលក្នុង១ដុល្លារអាមេរិក។ អត្រាប្តូរប្រាក់រៀល បានចុះថ្លៃបន្តិចបើប្រៀបធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ដែលនៅចន្លោះពី ៤.០៤៦ រៀលទៅ ៤.០៩២ រៀលក្នុង១ដុល្លារអាមេរិក។ បម្រែបម្រួលនេះ មួយផ្នែកបណ្តាលមកពីធនាគារកណ្តាលនៃសហរដ្ឋអាមេរិក បានតម្លើងអត្រាការប្រាក់មូលនិធិសហព័ន្ធរបស់ខ្លួន ដើម្បីទប់ទល់នឹងកំណើនអតិផរណានៃប្រាក់ដុល្លារអាមេរិក។ ប្រមើលមើលទៅមុខ តម្លៃប្រាក់រៀលត្រូវបានរំពឹងថានឹងរក្សាស្ថិរភាពដោយយោងលើតម្រូវការនិងការផ្គត់ផ្គង់នៅលើទីផ្សារ សាធារណៈជនមានទំនុកចិត្តលើការប្រើប្រាស់ប្រាក់រៀល និងសន្ទុះងើបឡើងវិញនៃសកម្មភាពសេដ្ឋកិច្ច ក្រោមការត្រួតពិនិត្យយ៉ាងហ្មត់ចត់ពីធនាគារជាតិនៃ កម្ពុជា។

ការប្រែប្រួលដូចបានរៀបរាប់ខាងលើនេះ មិនមានផលប៉ះពាល់ជាសារវន្តដល់ធនាគារ អេស៊ីលីដា ឡើយ ព្រោះថា ធនាគារបានរាស់វែង ត្រួតពិនិត្យ និងចាត់ចែងរក្សាជាប្រចាំនូវស្ថានភាពរូបិយប័ណ្ណចំហឱ្យនៅកម្រិតតូចល្មម និងអនុវត្តតាមបទប្បញ្ញត្តិរបស់ធនាគារជាតិ នៃ កម្ពុជា និងគោលនយោបាយហានិភ័យផ្ទៃក្នុងរបស់ធនាគារ។

ការរឹតបន្តឹងនៃគោលនយោបាយរូបិយវត្ថុរបស់សហរដ្ឋអាមេរិក បានអូសបន្លាយវែងហួសពីការរំពឹងទុកបណ្តាលឱ្យអត្រាការប្រាក់ទាំងទីផ្សារក្នុងស្រុក និងអន្តរជាតិបានបន្តរក្សានៅកម្រិតខ្ពស់ផងដែរ។ អត្រាការប្រាក់មូលនិធិសហព័ន្ធរបស់សហរដ្ឋអាមេរិកនៅតែស្ថិតនៅកម្រិតខ្ពស់ដើម្បីទប់ទល់នឹងអតិផរណារបស់ខ្លួន។

សម្រាប់ធនាគារ អេស៊ីលីដា បម្រែបម្រួលនៃអត្រាការប្រាក់មានផលប៉ះពាល់តិចតួចបំផុតដល់អាជីវកម្មរបស់ធនាគារ ដោយសារប្រតិបត្តិការអាជីវកម្មរបស់ធនាគារ ស្ទើរតែទាំងស្រុងបាននិងកំពុងប្រើប្រាស់ទ្រព្យសកម្ម និងទ្រព្យអកម្មដែលមានអត្រាការប្រាក់ថេរ។ លើសពីនេះ ធនាគារបានត្រួតពិនិត្យជាប្រចាំ សម្រាប់ចាត់វិធានការសមស្រប និងទាន់ពេលវេលា ដើម្បីជៀសវាងផលប៉ះពាល់ដល់អាជីវកម្មរបស់ធនាគារ។

ចំពោះប្រតិបត្តិការជួញដូរនានា ដែលមានទម្រង់ជាទំនិញ (Commodities) ធនាគារមិនមានផ្តល់សេវាបែបនោះទេ។ ដូច្នេះមិនមានផលប៉ះពាល់ដល់ធនាគារឡើយ។

## ង- ផលប៉ះពាល់នៃអតិផរណា

អតិផរណាត្រូវបានរំពឹងថានឹងវិលមកសភាពធម្មតាវិញ នៅអត្រា២,៥% សម្រាប់ឆ្នាំ២០២៣ និង២០២៤ ដោយយោងលើការរំពឹងទុកនៃតម្លៃប្រេង និងទំនិញសកល ដែលនឹងត្រឡប់មកសភាពធម្មតាវិញ។ ដោយឡែកចំពោះប្រតិបត្តិការរបស់ធនាគារ អេស៊ីលីដា គឺពុំមានទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងកម្រិតអតិផរណាទេ ដូចនេះផលប៉ះពាល់មានតិចតួចបំផុត និងអាចគ្រប់គ្រងបាន។

## ច- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល

- <u>គោលនយោបាយសេដ្ឋកិច្ចៈ</u>

ធនាគារជាតិ នៃ កម្ពុជា បានផ្តល់ជារបាយការណ៍ថា សេដ្ឋកិច្ចកម្ពុជាឆ្នាំ២០២៣ រំពឹងថានឹងបន្តកើនឡើងក្នុងរង្វង់ ៥,៥% ហើយអត្រាអតិផរណាត្រូវបានព្យាករថានឹងថយចុះមកក្នុងរង្វង់ ២% វិញ ដោយសារថ្លៃប្រេងឥន្ធនៈត្រូវបានព្យាករថានឹងថមថយក្នុងស្ថានភាពដែលសេដ្ឋកិច្ចពិភពលោកមានកំណើនយឺតជាងឆ្នាំមុន និងភាពប្រសើរឡើងនៃច្រវាក់ផ្គត់ផ្គង់សកល ដែលគាំទ្រជាចម្បងដោយកំណើនវិស័យទេសចរណ៍ និងវឌ្ឍនភាពល្អនៃវិស័យកសិកម្ម ស្របពេលដែលវិស័យសំណង់ហាក់បានបង្ហាញពីសញ្ញាងើបឡើងវិញខណៈដែលការនាំចេញក្នុងវិស័យកាត់ដេរ ស្បែកជើងនិងផលិតផលធ្វើដំណើរទៅកាន់ប្រទេសដៃគូសំខាន់ៗបានធ្លាក់ចុះដោយសារតែ

សេដ្ឋកិច្ចប្រទេសទាំងនោះទទួលរងផលប៉ះពាល់ពីការអូសបន្លាយនៃសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន និងឥទ្ធិពលអវិជ្ជមាននៃការដំឡើងអត្រាការប្រាក់គោលដើម្បីទប់ទល់នឹងកំណើនអតិផរណា ដែលរួមមាន៖

១. វិស័យកម្មន្តសាល បានទទួលរងផលប៉ះពាល់ដោយសារការថយចុះ នៃតម្រូវការខាងក្រៅ ជាពិសេស សហរដ្ឋអាមេរិក និងអឺរ៉ុប។ តម្លៃផលិតផលកម្មន្តសាលសរុប ថយចុះ ១៦,១% (ពីមួយឆ្នាំទៅមួយឆ្នាំ) ដែលក្នុងនោះផលិតផលកម្មន្តសាលសម្រាប់នាំចេញថយចុះ ១៩,៨% ស្របពេលដែលផលិតផលកម្មន្តសាលបម្រើទីផ្សារក្នុងស្រុកថយចុះ ៧,៨%។

២. វិស័យទេសចរណ៍មានកំណើន ខ្ពស់ជាងការរំពឹងទុក ដោយក្នុងឆមាសទី១ ឆ្នាំ២០២៣ នេះប្រទេសកម្ពុជាបានរៀបចំព្រឹត្តិការណ៍ធំៗជាច្រើន ដូចជា ព្រឹត្តិការណ៍អង្គរសង្ក្រាន្ត កីឡាស៊ីហ្គេម និងអាស៊ានប៉ារ៉ាហ្គេមដែលព្រឹត្តិការណ៍ទាំងនេះបានជួយស្រូបទាញកំណើនទេសចរអន្តរជាតិចូលមកប្រទេសកម្ពុជាកាន់តែច្រើនជាងមុន។ ភ្ញៀវអន្តរជាតិកើនឡើងដល់ប្រមាណ ២,៦ លាននាក់ (កើន ៥,១ ដង ពីមួយឆ្នាំទៅមួយឆ្នាំ) ដោយភ្ញៀវថៃបន្តឈរនៅលំដាប់ទី១នៃភ្ញៀវអន្តរជាតិដែលមកកម្សាន្តនៅប្រទេសកម្ពុជា(សមាមាត្រ ៣៨%) បន្ទាប់មកភ្ញៀវវៀតណាម (១៨%) និងចិន (១០%)។

៣. វិស័យសំណង់ បានងើបឡើងមកវិញ ដែលឆ្លុះបញ្ចាំងតាមរយៈកំណើននៃការនាំចូលសម្ភារនិងបរិក្ខារសំណង់ (០,៤%)។ ចំពោះគម្រោងសាងសង់ដែលទទួលការអនុម័ត តម្លៃនិងផ្ទៃក្រឡាគម្រោងសាងសង់ ត្រូវបានប៉ាន់ស្មានថាមានកំណើន ១,៣ដង ( ពីមួយឆ្នាំទៅមួយឆ្នាំ) ខណៈចំនួនគម្រោងបានថយចុះ ៩%។

៤. វិស័យកសិកម្មបន្តមានវឌ្ឍនភាពល្អ ដែលឆ្លុះបញ្ចាំងតាមរយៈកំណើនដំណាំស្រូវនិងកៅស៊ូ និងអនុវិស័យជលផល។ ផលស្រូវរដូវប្រាំងសម្រេចបានកំណើនខ្ពស់ប្រមាណ ១៣% ធៀបនឹងគ្រាដូចគ្នាឆ្នាំមុន (០,២% ឆ្នាំមុន) ដល់ប្រមាណ ៣,៣លានតោន ស្របពេលដែលផ្ទៃដាំដុះស្រូវរដូវវស្សាបានកើន ១៨,៧% (ពីមួយឆ្នាំទៅមួយឆ្នាំ) ដោយសារកត្តាអំណោយផលពីអាកាសធាតុ ដែលបានផ្តល់ទឹកគ្រប់គ្រាន់សម្រាប់កសិករបង្កបង្កើនផល។

៥. សមតុល្យជញ្ជីងទូទាត់កម្ពុជាត្រូវបានប៉ាន់ស្មានថាមានអតិរេក ២២៥ លានដុល្លារអាមេរិក ដែលគាំទ្រសោយលំហូរចូលសុទ្ធនៃគណនីហិរញ្ញវត្ថុ ស្របពេលដែលឱនភាពគណនីចរន្តនិងដើមទុនបានប្តូរទៅជាអតិរេក ព្រមទាំងបានរួមចំណែករក្សាទុនបម្រុងអន្តរជាតិឱ្យស្ថិតក្នុងកម្រិតខ្ពស់គ្រប់គ្រាន់ ដែលអាចធានាការនាំចូលទំនិញ និងសេវាសម្រាប់គ្រាបន្ទាប់បានប្រមាណ ៧ខែ ខ្ពស់ជាងកម្រិតអប្បបរមាសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍គួរមាន (៣ខែ)។

ស្របគ្នានេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក៏បានព្យាករផងដែរថា សេដ្ឋកិច្ចកម្ពុជាត្រូវបានវាយតម្លៃថានឹងសម្រេចបានកំណើនក្នុងអត្រា ៥,៦% ដូចតាមការប៉ាន់ស្មានកាលពីដើមឆ្នាំ ប៉ុន្តែអនុវិស័យដែលគាំទ្រកំណើនខ្លះមានការប្រែប្រួល។ ផលវិបាកនៃសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន, សង្គ្រាមពាណិជ្ជកម្ម និងបច្ចេកវិទ្យារវាងចិន-អាមេរិក និងការបន្តរឹតបន្តឹងគោលនយោបាយរូបិយវត្ថុក្នុងបណ្តាប្រទេសអភិវឌ្ឍន៍ កំពុងធ្វើឱ្យទស្សនវិស័យសេដ្ឋកិច្ចសកលបន្តមានភាពមិនប្រាកដប្រជាខ្ពស់ និងបានដាក់សម្ពាធមកលើអនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ និងការងើបឡើងវិញនៃអនុវិស័យសណ្ឋាគារនិងភោជនីយដ្ឋាន និងវិស័យគាំទ្រផ្សេងៗទៀត រួមមានលក់ដុំ-រាយ និងដឹកជញ្ជូន បន្តចូលរួមចំណែកទ្រទ្រង់កំណើនសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០២៣។ [១],[២]

យោងតាមព័ត៌មានដែលបានចុះផ្សាយរបស់ស្ថាប័នល្បីល្បាញមួយចំនួននៅបន្តព្យាករ GDP ឆ្នាំ២០២៣ របស់កម្ពុជាផងដែរ។ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានព្យាករសេដ្ឋកិច្ចរបស់កម្ពុជាថានឹងកើនឡើង ៥,៥% ក្នុងឆ្នាំ២០២៣ និង ៦% ក្នុងឆ្នាំ២០២៤ លើការស្ទុះងើបឡើងវិញនៃវិស័យទេសចរណ៍ដ៏រឹងមាំ និងកំណើនខ្ពស់ក្នុងវិស័យសេវាកម្ម។ ទស្សនវិស័យអភិវឌ្ឍន៍អាស៊ី (ADO) ខែមេសា ឆ្នាំ២០២៣ និយាយថា វិស័យទេសចរណ៍ត្រូវបានគេរំពឹងថានឹងកើនឡើង ៧,៣% នៅឆ្នាំ២០២៣ មុនពេលបន្ធូរបន្ថយមកត្រឹម ៦,៨% នៅឆ្នាំ២០២៤។ ទិន្នផលឧស្សាហកម្មត្រូវបានគេរំពឹងថានឹងកើនឡើង ៥,៨% ក្នុងឆ្នាំ២០២៣ មុនពេលបង្កើនល្បឿនដល់ ៧,៨% ក្នុងឆ្នាំ២០២៤។ កំណើនសំណង់ត្រូវបានគេរំពឹងថានឹងនៅតែយឺត។ វិស័យកសិកម្មត្រូវបានព្យាករថានឹងកើនឡើង ១,១% នៅឆ្នាំនេះ និង ១,២% ក្នុងឆ្នាំ២០២៤ ដែលត្រូវបានជំរុញដោយផលិតកម្មដំណាំសម្រាប់ការនាំចេញ។ មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានព្យាករថា GDP សម្រាប់ប្រទេសកម្ពុជាគឺ ៥,៨% សម្រាប់២០២៣ និង ៦,២% សម្រាប់២០២៤ នេះបើយោងតាមការចុះផ្សាយនៅលើគេហទំព័ររបស់ពួកគេ។ ធនាគារពិភពលោកបានព្យាករកំណើន GDP ពិតប្រាកដរបស់កម្ពុជាសម្រាប់ឆ្នាំ២០២៣ ថានឹងកើនឡើងបន្ថែមទៀត ដោយឈានដល់ ៥,៥%។ ទោះបីជាមានការបន្ធូរបន្ថយនៃការនាំចេញទំនិញក៏ដោយ ឱនភាពគណនីចរន្តត្រូវបានគេរំពឹងថានឹងមានភាពប្រសើរឡើងដល់ ១៩,៣% នៃផលិតផលក្នុងស្រុកសរុប (GDP) ដោយសារការងើបឡើងវិញនៃសេវាកម្ម ការនាំចេញ ជាពិសេសសំដៅទៅលើ

ចំណូលពីវិស័យទេសចរណ៍ និងការផ្ទេរប្រាក់។ ទោះបីជាមានការធ្លាក់ចុះនៃគម្រោង FDI ដែលត្រូវបានអនុម័តនាពេលថ្មីៗនេះក៏ដោយ លំហូរទុនដ៏រឹងមាំ និងការផ្តល់ហិរញ្ញប្បទានសម្បទាននឹងបន្តគ្របដណ្តប់យ៉ាងទូលំទូលាយនូវតម្រូវការហិរញ្ញប្បទានពីខាងក្រៅ។ [៣, ៤, ៥]

## ▪ គោលនយោបាយសារពើពន្ធ៖

សម្រាប់ឆ្នាំ២០២៣ អគ្គនាយកដ្ឋានពន្ធដារបានដាក់ចេញនូវវិធានការសំខាន់ៗ និងជាយុទ្ធសាស្ត្រសំខាន់ៗដូចតទៅ៖

(១) បន្តយកចិត្តទុកដាក់ និងពង្រឹងការអនុវត្តការងារស្របតាមអនុសាសន៍របស់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាទិសដៅអនុវត្តបន្តសម្រាប់ឆ្នាំ២០២៣ របស់អគ្គនាយកដ្ឋានពន្ធដារ កាលពីកិច្ចប្រជុំបូកសរុបលទ្ធផលប្រមូលចំណូលពន្ធប្រចាំឆ្នាំ២០២២ នាថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣។

(២) អនុវត្តផែនការសកម្មភាពក្នុងការផ្សព្វផ្សាយច្បាប់ស្តីពីសារពើពន្ធថ្មី ជូនដល់អ្នកជាប់ពន្ធ សាធារណជន ព្រមទាំងបន្តរៀបចំធ្វើបច្ចុប្បន្នភាពបទប្បញ្ញត្តិនានាស្តីពីពន្ធដារឱ្យស្របតាមច្បាប់ស្តីពីសារពើពន្ធថ្មី។

(៣) បន្តពង្រឹងការផ្តល់សេវាពិគ្រោះយោបល់ និងការផ្សព្វផ្សាយច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ តាមគ្រប់រូបភាពជាពិសេសការផ្តល់សេវាពិគ្រោះយោបល់តាមរយៈទូរស័ព្ទ (Call Center-1277) និងការរៀបចំកម្មវិធី "ពន្ធដារកម្ពុជា" (GDT Facebook Live) ដើម្បីពន្យល់និងដោះស្រាយការលំបាកនិងចម្ងល់របស់ប្រជាពលរដ្ឋ។

(៤) រៀបចំសិក្ខាសាលាជាមួយសមាគមសហគ្រិនវ័យក្មេងក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត ហ៊ុន ម៉ាណែត លើប្រធានបទពាក់ព័ន្ធនឹងអនុលោមភាពសារពើពន្ធ ក្នុងអំឡុងខែមិថុនា ឬកក្កដា ឆ្នាំ២០២៣។

(៥) ស្នើសុំសហការជាមួយក្រសួងពាណិជ្ជកម្មលើការពង្រឹងការចុះបញ្ជីសហគ្រាសថ្មីព្រមទាំងពង្រឹងប្រសិទ្ធភាពការងារ និងតួនាទីរបស់ភ្នាក់ងារចុះបញ្ជីពាណិជ្ជកម្ម។

(៦) បន្តពង្រឹងការគ្រប់គ្រងប្រមូលពន្ធ តម្លាភាព និងការប្រកួតប្រជែងដោយសេរីភាពក្នុងវិស័យផលិតភេសជ្ជៈ និងផលិតផលបារីនិងថ្នាំជក់ ដើម្បីធានាបាននូវនិរន្តរភាពចំណូលពន្ធដែលជាគុណប្រយោជន៍នៃថវិកាជាតិ។

(៧) រៀបចំប្រព័ន្ធដំណើរការការងាររដ្ឋបាលតាមទម្រង់ឌីជីថល (E-Administration) និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រដើម្បីអនុញ្ញាតឱ្យរដ្ឋបាលសារពើពន្ធអាចអនុវត្តការងារតាមឋានានុក្រម ដោយប្រើប្រាស់ទម្រង់ឌីជីថល និងធានាបាននូវល្បឿននិងប្រសិទ្ធភាពក្នុងការអនុវត្តការងារ។

(៨) បន្តអនុវត្តវិធានការទារនិងតឹងទារបំណុលពន្ធតាមនីតិវិធីជាធរមាន ចំពោះសហគ្រាសដែលជំពាក់បំណុលពន្ធហើយមិនបានចូលខ្លួនមកទូទាត់ឬដោះស្រាយឱ្យបានត្រឹមត្រូវ។

(៩) បន្តពង្រឹងការងារចុះបញ្ជីពន្ធដារនិងធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស និងបន្តសហការចូលរួមកែលម្អ និងជំរុញការងារចុះបញ្ជីសហគ្រាសតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន (CamDX) ឱ្យកាន់តែមានប្រសិទ្ធភាព និងមានភាពគ្រប់ជ្រុងជ្រោយ។

(១០) បន្តផ្សព្វផ្សាយនិងពង្រឹងការអនុវត្តវិធានវិក្កយបត្រក្នុងចំណោមអ្នកជាប់ពន្ធ និងកម្មវិធីវិក្កយបត្រនាំសំណាង (GDT Lucky Draw) ឱ្យមានការចូលរួមបន្ថែមទៀតពីសាធារណជន ដើម្បីធានាបាននូវប្រសិទ្ធភាពនិងតម្លាភាពក្នុងការគ្រប់គ្រងប្រមូលចំណូលពន្ធអាករនានា។

(១១) បន្តពង្រឹងការគ្រប់គ្រងសហគ្រាសស្នើសុំផ្អាកបណ្តោះអាសន្ន ឬស្នើសុំបើកដំណើរការឡើងវិញ និង/ព្យួរទុក ឬបើកដំណើរការវិញ្ញាបនបត្រអាករលើតម្លៃបន្ថែម។

(១២) បន្តពង្រឹងនិងយកចិត្តទុកដាក់ចំពោះការស្នើសុំបិទសហគ្រាសជាស្ថាពរ និងពង្រឹងលើការងារសវនកម្មសម្រាប់សហគ្រាសស្នើសុំបិទ។

(១៣) បន្តចូលរួមក្នុងក្របខ័ណ្ឌការងារប្រឆាំងនឹងបទល្មើសសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ជាមួយគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ (គ.ស.ហ.) និងអនុគណៈកម្មការចំពោះកិច្ចអនុវត្តផែនការសកម្មភាពការងាររបស់ក្រុមការងារត្រួតពិនិត្យរួម នៃក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកអំពីកិច្ចសហប្រតិបត្តិការអន្តរជាតិ (អ.អ.ផ.)។

(១៤) បន្តធ្វើទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងកម្មវិធីប្រកបដោយស្មារតីបុរេសកម្ម តាមរយៈការអភិវឌ្ឍនិងធ្វើបច្ចុប្បន្នភាពប្រព័ន្ធនិងកម្មវិធីថ្មីៗ បន្តវិនិយោគ និងអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងហេដ្ឋារចនាសម្ព័ន្ធគាំទ្រ និងពង្រឹងសមត្ថភាពមុខងារវិភាគទិន្នន័យបន្ថែមទៀត ដើម្បីជំរុញបង្កើនកម្រិតអនុលោមភាពសារពើពន្ធ ដោយធ្វើយ៉ាងណាឱ្យងាយស្រួលក្នុង

ការបំពេញកាតព្វកិច្ចពន្ធដារ ប៉ុន្តែពិបាកក្នុងការគេចវេះ តាមរយៈការបន្តអភិវឌ្ឍបន្ថែមនូវមុខងារមួយចំនួន តាមធាតុចូលដែលទទួលបានពីអ្នកប្រើប្រាស់ពីគ្រប់មជ្ឈដ្ឋាន ដើម្បីឱ្យកាន់តែមានភាពគ្រប់ជ្រុងជ្រោយនិងងាយស្រួលក្នុងការប្រើប្រាស់។

(១៥) បន្តអនុវត្តវិធានការបន្ថែមរបស់រាជរដ្ឋាភិបាលសម្រាប់បន្តគ្រប់គ្រងផលប៉ះពាល់ និងគាំទ្រការងើបឡើងវិញនៃវិស័យទេសចរណ៍នៅព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងបន្តកាត់បន្ថយផលប៉ះពាល់មកលើស្ថានភាពសង្គម-សេដ្ឋកិច្ច ព្រមទាំងបន្តជួយទ្រទ្រង់ និងស្តារអាជីវកម្ម និងធុរកិច្ចឱ្យងើបឡើងវិញ។

(១៦) អនុវត្តនូវវិធានការរបស់រាជរដ្ឋាភិបាលសម្រាប់គាំទ្រដល់ការអភិវឌ្ឍវិស័យសំណង់ និងអចលនទ្រព្យដើម្បីរក្សាស្ថិរភាពនៃវិស័យសំណង់ និងអចលនទ្រព្យ ដែលត្រូវបានចាត់ទុកជាវិស័យអាទិភាពមួយគាំទ្រដល់កំណើនសេដ្ឋកិច្ចជារួម។

(១៧) បន្តអនុវត្តវិធានការចាំបាច់នានាដូចមានកំណត់ក្នុងសារាចរណែនាំស្តីពីការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ និងបន្តអនុវត្តដោយការយកចិត្តទុកដាក់នូវយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣។ [៦]

សរុបរយៈពេល៦ខែ ឆ្នាំ២០២៣ ចំណូលពន្ធ-អាករ ដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបានជាក់ស្តែងតាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារ មានចំនួន ៨.៣៩៣,១៧ ប៊ីលានរៀល (ប្រមាណជា ២.០៧២,៣៩ លានដុល្លារអាមេរិក) ស្មើនឹង ៥៨,០២% នៃផែនការច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣។ ចំពោះលទ្ធផលនៃការគ្រប់គ្រងប្រមូលចំណូលពន្ធ បានបង្ហាញថា ក្នុងខែមិថុនា ឆ្នាំ២០២៣ ចំណូលពន្ធ-អាករគ្រប់ប្រភេទ ដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបានជាក់ស្តែងតាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារមានចំនួន ៩៩៥,០១ ប៊ីលានរៀល (ប្រមាណជា ២៤៥,៦៨ លានដុល្លារអាមេរិក) ស្មើនឹង ៦,៨៨% នៃផែនការច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣។ [៦]

- **គោលនយោបាយរូបិយវត្ថុ៖**

សម្រាប់ឆ្នាំ២០២៣ ធនាគារជាតិ នៃ កម្ពុជា បានកំណត់អនុវត្តន៍គោលនយោបាយរូបិយវត្ថុចំនួន៥ ដើម្បីគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការស្តារកំណើនសេដ្ឋកិច្ចជាតិ រួមមាន៖

(១) គ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុឱ្យស្ថិតក្នុងកម្រិតសមស្រប

(២) រក្សាស្ថិរភាពអត្រាប្តូរប្រាក់ ដើម្បីរួមចំណែកស្ថិរភាពថ្លៃ និងជំនឿទុកចិត្តរបស់សាធារណជន

(៣) លើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលតាមយន្តការទីផ្សារ

(៤) អភិវឌ្ឍឧបករណ៍គោលនយោបាយរូបិយវត្ថុថ្មីៗ និង

(៥) ជំរុញការអភិវឌ្ឍទីផ្សារអន្តរធនាគារ ក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុ។ [១]

ឯកសារយោង:


(១) https://www.nbc.gov.kh/download_files/publication/annual_rep_kh/Semi%20Annual%20Report%202023%20Publish_KHM.pdf

(២) https://mef.gov.kh/documents/9273/ Release on 04-Aug-2023

(៣) https://www.adb.org/news/cambodia-economy-accelerate-tourism-recovery-adb

(៤) https://www.imf.org/en/Publications/WEO/Issues/2023/04/11/world-economic-outlook-april-2023

(៥) https://documents1.worldbank.org/curated/en/099051523221517821/pdf/P17734003f2bcf02b0a89500f61b1f3ff7b.pdf

(៦) https://www.tax.gov.kh/u6rhf7ogbi6/gdtstream/4a00be95-27f8-48cb-a476-f3b7dcdcfa26


**ហត្ថលេខាអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ**

ថ្ងៃព្រហស្បតិ៍ ៩រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៣

បានអាន និងឯកភាព

ហត្ថលេខា

**ឆាយ សឿន**

**ប្រធានក្រុមប្រឹក្សាភិបាល**

ការិយាល័យកណ្តាល ៖ អគារលេខ៦១ មហាវិថីព្រះមុនីវង្ស
សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០២៣ ៩៩៨ ៧៧៧ / ៤៣០ ៩៩៩ | ទូរសារ ៖ ០២៣ ៤៣០ ៥៥៥
acledabank@acledabank.com.kh | www.acledabank.com.kh
ប្រអប់សំបុត្រលេខ ៖ ១១៤៩ | SWIFT Code ៖ ACLBKHPP

ការិយាល័យទំនាក់ទំនងអតិថិជន (បម្រើ ២៤ម៉ោង)
ទូរស័ព្ទ ៖ ០២៣ ៩៩៤ ៤៤៤, ០១៥ ៩៩៩ ២៣៣
inquiry@acledabank.com.kh